# [illegible]

— ទីតាំងការិយាល័យក្រុមអ្នកនិពន្ធមាតុភូមិ ផ្ទះលេខ ២៥ ផ្លូវលេខ ២៥៥ [illegible] បឹងកេងកង សង្កាត់លេខ ៥ ក្រុងភ្នំពេញ —

ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ

Khmer Story Lovers



អ្នកប្រែសម្រួល: ង.គឹមសាន

តម្លៃ ២៥ រ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ

«មាតុភូមិ»

ភ្នំពេញ

លេខ ៣១

## វគ្គទី ២៩

## ខំភាត់មកពីចម្ងាយដើម្បីមិត្ត

ក្តីកាលគ្នាឃើញរាងកាយស៊ីផងាន លោកតេចភ្វីប ភ្ញៀតតាមចន្លោះស្រមោលវាំងនត, មើលពីក្រៅហាក់ដូចស្ងាត់ស្ងៀម ព្រោះថ្នាក់ខ្លួនណាស់

ស៊ីផងានក្តៅក្តីស្លូតក្នុងចិត្ត:

– ហេតុអីលោកតាទង់មិនហួសប៉ួន មិនវាយលុកយើងមក ? គាត់ធ្វើកំប្លែងនឹងយើងឬ បានជាត្រូវគ្រវាត់តែក្បួរ ៗ ឲ្យយើងភ័យ ?

ការពិតគីទង់មិនហួសប៉ួនបញ្ចេញឥទ្ធិពលនិងចំណេះអស់ពីខ្លួនហើយ, នៅខ្វះតែប្រហែលមួយចំអាមសោះ គាត់វាយត្រូវនាយស្រេច ។ ទីងតុងធ្លាប់ស្គាល់ជីតា ធ្លាប់ដឹងចិត្តគាត់កាចលេខមួយ, បើគាត់បញ្ចេញស្នៀតពិសេសមក «ប្ញ» ទាំងច្បាស់ជាស្លាប់ក្រោមស្នាដៃគាត់ហើយ ។ ទាំងតាមមើលយូរទៅតែភ័យស្លុត ក៏ស្រែកប្រាប់មាណពភ្លាម :

– បងងាន, ឆាប់តដៃវិញភ្លាមទៅ ! បើមិនតដៃច្បាស់ជាវិវរហើយបង !

ទាំងអស់គ្នា ពួកវាចាស្រួយស្រេះចេញពីមាត់អ្នកបំរើដូច្នេះ ក៏

គេជឿថាខ្លួនជាខ្លាំង,ហើយចាំមើលគេទៅទៀត ។

ស៊ីផានញញឹមមាត់ក្រពុំ ឆ្លើយតិចៗថា :

–ហេតុអ្វីបានជាអីវ៉ៃ? អ្នកមិនដឹង! ថ្ងៃមួយនោះយើងចងដៃម្ខាងប្រយុទ្ធនឹងក្រុមកសិករស្រុកសាំទកប៉ង អស់លោកទាំងអស់ តោងថា យើងបើកវាយប៉ះលហែកលោក ៗ ម៉្យាងទៀតខ្ញុំយើង ក៏បានរំពឹងដែរថា ចូលប្រយុទ្ធជាមួយគេតែម្នាក់ទៀតដែលគេអាចទៅប្រកាន់បាន ៗ ហើយយើងប្រយុទ្ធឈ្នះគេក៏បានអីទេ តែបើបែរជាពោះពោតប្រែមកវាយយើងវិញ យើងនឹងក្លាយជាសត្រូវស្លាប់រស់ប្រចាំជីវិតគេមិនខាន ។ ពេលនេះបើយើងចេះតែលេកគេច ប្រហែលគាត់មិនហួសប្អូនយល់ថា យើងមាកក្រោយគាត់ណា!

ស៊ីផានគិតឃើញដូច្នេះ ក៏លូកដៃចាំងពាំងតាមខ្សែស្រូនពាធាសំតាមស្មៀកចាប់ខ្ញុំ ដែលរលួយធំទំនុង ៗ ទីងមិនហួសប្អូនស្គាល់ស្មៀកចាប់ខ្ញុំប្រចាំត្រកូលរចូសណាស់, ប៉ុន្តែពេលមាណពលូក ចាប់ខាំនោះគម្ងាំងធាតុទាយរត់ចេញទៅជាមួយពួសន្ទុកខ្យល់ខ្ទុះខ្ទារ ភាបាសំលែងស្គាល់ស្មៀកកាត់រងបេះ ទៅជាភ័យរន្ធត់ស្រែកភ្ញាក់សាម្លង :

– ថ្ងៃនេះខ្មោចលងអញហើយ !

អ្នកទាំងពីរប្រយុទ្ធគ្នាបានដប់ពីរស្មៀក, ស៊ីផានក្រឡាប់ដៃប្រើស្មៀកក្ដេះក្លាកចាប់ចុងរពាត់មាសដាប់ ៗ ទីងមិនហួសប្អូនទំបំរើនកម្លាំងធាតុកន្ត្រាក់ហក់ត្រឡប់ តែពោះម៉េចរង្គើសោះ គាត់ស្រែកភាំសស៊ីរបែកករកាស បញ្ចេញកម្លាំងអស់ពីខ្លួនទាញទៅក្រោយអស់ទំហឹង ព្រមទាំងនិយាយថា :

– យើងមិនចូលចិត្តឲ្យអ្នកណាប្រើកាត់ក្បាច់ប្លុកគំពកក់ជាអាវុធទេ ហើយពេលនេះបើឲ្យអាក្មេងចង្រៃដណ្ដើមយកពីដៃចំពោះមុខមនុស្សមួយហ្វូងដូច្នេះ យើងយកមុខទៅទុកណា ?

ព្រោះហេតុតែតាស់ខ្ញាបកេបាស់មុខគណ្ដាលហ្វូងដូច្នេះហើយ ទំបំរើនកម្លាំងធាតុ ដណ្ដើមរំពាត់បកវិញលាន់ឮដៃខ្នុងក្រាកៗ ... ស៊ីផានឃើញបែបនេះនឹកគួរចិត្តថា:

–បើតាទីហួសប្អូនចង់បានរំពាត់ទៅវិញ ទបើងត្រូវតែលែងដៃ ៗ

គិតឃើញដូច្នេះមាណពលែងដៃភ្លាម ពុំសួរវី' ក្រាំង១ . . ព្រាំ២ ... គឺរូបកាយស្ដុមខ្ពស់របស់ទីងមិនហួសប្អូនបុីងផុតដី ខ្លួនទៅប៉ះជញ្ជាំងតៀមលក់បាយធាយដល់ក្នុង រលំតុកៅអីបែកខ្ទេច តែមួយប្រេល ! បន្ទាប់មកទៀតពួសប្រែកការណោចអាច័មនៃសិស្សគណមកពីលាទីតុងបប្អូនកាក់ គឺជន

កំផ្លីនោះផ្ដួលស្ដូកស្ដឹង ឈាមហូរញ៉ាំចេញពីខ្នងកលោគ្បូព្រឹក្បាល ។

ស៊ីផានប្រញាប់រត់ទៅមើលជនរងគ្រោះឃើញបុគ្គលនឹងអំបែងចានចិនកែវខ្ទូរទ្រហឹង ព្រមពេលដែលទីងមិនហួសបួនរត់ទៅណា បាត់ស្រមោលស្រេច ។

ក្បួនតាហាស់ដឹងខ្លួនប្រយុទ្ធមិនឈ្នះស៊ីផាន ក៏ប្រញាប់រត់ចាកចេញពីទីនេះ ពោរពេញដោយកំហឹងពេញទ្រូងហើយគាត់ភ្លៀតពេលបន្តិចបន្តួចនោះទៅលក់ទេចបានដឹងកែវសម្លាប់មនុស្សបួននាក់ទៀត ។

អ្នកក្លាហានតាំងអស់ទៅតំបន់សារគុនម្ចាស់ហ៊ានរត់ទៅជួយលើកជនរងគ្រោះ តែគេត្រូវបួសបំកន្ទែងសំរាន់ៗដាច់ខ្យល់ស្លាប់បាត់ទៅហើយ ។

អ្នកពល់គ្នាឃើញអំពើមនុស្សធម៌របស់ទីងមិនហួសបួនផ្ចាល់ក្អកបែបនេះ កក់កក់ភ័យញ័ររន្ធត់ ទឹកប៉ារប៉ឺកុំតែបានស៊ីផានជួយប៉ុណ្ណឹងម៉េះសមខាយក្រុមតាំងបួនស្លាប់ជំនួសជនពស់នេះទៅហើយ ។

គេនាំគាស់ស៊ីផានទៅកាន់អ្នកកម្លោះ ថ្លែងអំណរគុណដោយបន្ទូលថា:

– អ្នកក្លាហានបានជួយយើងខ្ញុំប៉ុណ្ណេះ យើងខ្ញុំនឹងចងចាំមហាឧបការគុណនេះអស់មួយជីវិត តើអ្នកមាននាមថាម៉េចដែរ ?

ស៊ីផានចេះសុជីវធម៌ , ចេះគោរពការគួរសមដូចអ្នកក្លាហានផងទាំងពួងតាមការណែនាំរបស់អ្នកស្រីរុនបុះ ។ ខាយប្រញាប់លំឱនកាយធ្វើគារវៈតិចៗតបវិញស្រួលទាំងពោល :

– សូមអស់លោកកុំគួរសមពេក , ជួយប៉ុណ្ណឹង ចាំបាច់គុណស្រីយ៉ាង ? ខ្ញុំមានត្រកូលស៊ុ ឈ្មោះផុកយី ។

អ្នកទាំងអស់បែរទៅគួរសមនឹងស្ត្រីឈ្មោះទីងតុង់ទៀត ។

ស៊ីផានឆ្លើយជំនួស:

– នាងឈ្មោះទីង១ តុង១ , ត្រូវជា...ត្រូវជា...

ហាកពពួកក្រុមយុទ្ធនិយាយតទៅទៀតលែងបាន ។ ពួកហ្វានយីហ្វៀស្ទុកតែជាហាស់ចុំផ្លាប់មានការពិសោធន៍ គេយល់ថាយុវជនប្រុសស្រីក្លុងខ្លួនរួមដំណើរជាមួយគ្នាបែបនេះ ច្បាស់ជាមានរឿងការចិត្តចាំងលាក់នឹងអ្នកដំណើរដូចគ្នាហើយ ។ ហេតុនេះគេមិនហ៊ានសាកសួរទៀតឡើយ ។

មួយសន្ទុះក្រោយ ទីងតុងបបួល:

– មក ! យើងលួចបន្តដំណើរទៅទៀត ឬ ?

Khmer Story Lovers



ស៊ីងឆានប្រញាប់ប្រញាល់លើកដៃគោរពលាអ្នកក្លាហានទាំងអស់ ៗ ហើយយីហៀជូនដំណើរនាយចេញទៅ ដោយពោលពាក្យអរគុណចប់តាមផ្លូវ ៗ អ្នកទាំងនោះចង់ស្គាល់ប្រវត្តិអ្នកកម្លោះណាស់ តែដោយទីងតុងចេះតែធ្វើសញ្ញាហាមឃាត់ញឹកញយពេក ហាក់មិនចង់ឲ្យគេណារំខាននាងពេក ទើបគេមិនហ៊ានសួរ តែពោលថា :

- លោកស៊ីមានគុណធំធេងលើពួកខ្ញុំ, ប្រហែលពួកខ្ញុំគ្មានពេលតបស្នងសងគុណលោកឲ្យបានពេញចិត្តទេ ហេតុនេះបើថ្ងៃក្រោយលោកមានការអ្វីអាចឲ្យពួកយើងជួយបាន សូមប្រាប់យើងខ្ញុំផង, ទោះចូលសមុទ្រភ្លើងឬដើរកាត់មុខដាវលំពែងក៏យើងខ្ញុំមិនរួញរាដែរ ៗ

ស៊ីងឆាននឹកដល់បណ្ដាំម្ដាយ នាយឆ្លើយតបយ៉ាងសុភាព

- យើងសុទ្ធជាត្រកូលអ្នកគុនដូចគ្នា គួរតែជួយគ្នាដូច្នេះហើយ ៗ ខ្ញុំយល់ថាអំពើល្អជាករណីយកិច្ចអ្នកក្លាហានក្នុងលោកទេតើ ! បើសិនលោកនៅគួរសមពេក, ខ្ញុំពិបាកចិត្តណាស់ ៗ ថ្ងៃនេះខ្ញុំបានស្គាល់លោក ហើយបានកម្រោគក្លាយជាមិត្ត ខ្ញុំរីករាយណាស់ ៗ

ហាន យៅហ្វេ និងគ្នីគ្នា បាននាយជួយជុំពីគ្រោះថ្នាក់ដល់ជីវិតគេត្រេកអរដូចបានរស់ម្ដងទៀត, ពេលនេះឃើញនាយនៅក្មេងក្ដីខ្លាំងក្លាហើយមានបុគ្គលសុភាពរាបសារពីពេក គេនាំគ្នាគោរពសរសើរនាយទ្វេឡើងមិនដាច់ចិត្តបែកគ្នាត្រង់ណោះសោះ ៗ

ចំណែកចៅងក្នុងឃើញ "បងធាន" នាងចេះប្រើសំដីផ្អែមផ្អូរ, គោរពតីចេះគួរសម នាងត្រេកអរណាស់ពោលថា :

- នរណាថាបងធានក្ដូក ? ពេលនេះសត្វតាក់ការចំតែក្លាយស្វាងហើយតើ !

នាងក្រមុំលួចញញឹមឡើងដងលេចសម្រស់គួរឲ្យប្រតី, តែនាងលាបច្បងពេញមុខ ហើយសៀតពាក់ខោអាវអ្នកបំរើធ្វើឲ្យគេចង់សើចទៅវិញ ៗ លោកស្រីការសភាចណាងផ ចាប់ដៃនាងពោលទាំងញញឹម:

- អ្នកបំរើម្នាក់នេះស្រស់ប្រិមប្រិយណាស់ ហើយពាក់ក្រវិលទៀត ពិតជាល្អប្លែកលើសអ្នកបំរើនៅស្រុកណាក្នុងយើងខ្ញុំមែន !

ទាំងអស់គ្នាសើចគឹកកងឡើង, ទីងតុងអស់សំណើចខ្ទប់ងដែរ និយាយថា :

- អម្បាញ់មិញអាលីយៀតៃភ័យខ្លាំងលោកតាចប្អូន ភ្លេចផ្លាស់ខោអាវក្មេងដោះក្រវិលទុកឲ្យឃើញ !

កាសានណាវ៉ាឃើញអ្នកស្រុកផ្អើលព្រួតគ្នាមកមើលពេញហ្វូយ គាត់វង្វេងស្មារតី នាកប្រយុទ្ធ សាហាវអម្បាញ់មិញពិតជាលេចឮគ្រប់ផ្ទះហើយ ទើបគេមកមើលច្រើនម្ល៉េះ ។ ទីនមិនហ៊ានបន្ត សម្លាប់គេបន្តទៀត , ព្រោះអ្នកស្រុកយល់ច្បាស់ថា ពួកយើងជាចោរព្រៃតាមគេចពីទីនេះ ឲ្យឆាប់ ។ លោកស្រីស្រែកប្រាប់គ្នា :

— យើងនៅទីនេះយូរមិនបានទេ , ឆាប់ចេញដំណើរភ្លាមឡើង !

គាត់ងាកទៅរកទីនតុនពោលទៀត :

-អូនស្រី, អ្នកតែងខ្លួនដូចព្រះប៉ារីហាលជ្រៅក្រៀមទោអាវខាងក្នុងអស់ហើយ ។ បងយក សំលៀកបំពាក់តាមខ្លួនមកច្រើនណាស់ , បើមិនយល់ទាស់ទេ , យើងទៅរកផ្ទះសុំណាក់មួយ ផ្លាស់សម្លៀកបំពាក់ជម្រះកាយផ្លាស់ខោអាវនេះចោលទៅ ។ អូនស្រីអើយ, ទេពធីតានៅស្រុកផាំងណាន ល្អដូចរូបអូន, បងមិនដែលប្រទះទេ ។ បងចង់មើលមុខមាត់អូននៅពេលស្លៀកពាក់ជាស្ត្រីម្តង តើដូចរូបគំនូររបស់វិចិត្រករដែរឬទេ ? ដល់បងត្រឡប់ទៅលានតុនវិញ ស្រួលអួតប្រាប់បងប្អូន នោះណា !

ទីនតុនជានារីពុលប៉ុងមែនហើយ ធ្លាប់រស់នៅក្នុងព្រៃភ្នំជាមួយពីតាដើរល្បងព្រៃតាមពិតពិតគុន មិន សូវដែលបានស្តាប់សំដីផ្អែមល្ហែមពីស្ត្រីដូចគ្នាដូចពេលនេះទេ ។ នាងសប្បាយរីករាយណាស់ លើកដៃខ្ទប់មាត់សើចហើយតបថា:

— ខ្ញុំមិនទាន់ស្លៀកតែងខ្លួនទេ, សូមបងស្រីកុំសើចអី ។

ស៊ីផ្ការនពោលកាត់ទាំងញញឹម :

— កាលនៅផ្ទះ... អូន . យប់នោះ .. អូនតែងខ្លួនល្អមើលណាស់ ។

មាណពចង់ពោលសរសើរពីសម្រស់នាងក្រមុំនាក់ត្រីដែលទីនមិនហ៊ានបញ្ចូលឲ្យរៀបការ ជាមួយទីន តុនតែនាយអៀនខ្មាសពេកនិយាយរអាក់រអួល, ទីនតុនសម្លឹងនាយលៀនអណ្តាតញាក់មុខ ។ កា សានណាវ៉ាយល់ថានាងក្រមុំព្រមហើយទើបលើកដៃឲ្យសញ្ញាចេញដំណើរ:

— ពួកយើងទៅមុខ !

អ្នកឯទៀតឆ្លើយតបយ៉ាងគឹកកង ហើយដឹកសេះមួយគូមកជូនស៊ីផ្ការនទីនតុនឡើងជិះមុន ។ បន្ទាប់មកទើបគេកាន់គ្នាឡើងជិះតាមចេញពីផ្លូវនោះ ដោយនាំសាកសពមួយទៅតាមផង ។

បើនិយាយពីគំនិតយុទ្ធសិល្បៈនិងកាយុ, ហ្វានយីហ្វៃត្រូវធ្វើមេដឹកនាំជនមួយក្រុមនេះ ។ ប៉ុន្តែដោយហេតុថាគូមិនហ៊ានបានមើលចេញសោហ៊ុយសព្វសារពើក្នុងការធ្វើដំណើរ ៖ ទើបគេលើកលោកស្រីការសានលានជីឲ្យដឹកនាំវិញ ។ លោកស្រីចាយប្រាក់ដូចក្រដាស, ចិត្តទូលាយណាស់ ។ ដំរិះចាំងអស់សុទ្ធតែរើសរកតែទុនល្អរត់លឿនក្រៃលែង, មួយៗក្នុងពោះបានបង្ហាយជាងដប់យោជន៍ស្រេច ។ ស៊ីផានល្មួចសួរទឹងតុងគិប ៖

- នេះជាផ្លូវទៅកាន់ស្រុកជាស៊ីឬ ?

ទឹងតុងងក់ក្បាលញញឹមខ្ចឹប ព្រោះស្រុកជាស៊ីនៅទិសអគ្នេយ៍ តែគេធ្វើដំណើរសំដៅទិសខាងលិចដូច្នេះបានសេចក្តីថា រឹតតែឃ្លាតឆ្ងាយពីប្តីប្រពន្ធស៊ីណឹងថែមទៀង ។ នៅពេលជិតព្រលប់គេទៅដល់ស្រុកគីងយាងជាទីប្រជុំជនមួយធំ ។ ទាំងអស់គ្នាសំរាកផ្ទះសំណាក់យ៉ាងធំ ដើម្បីចាំវេចន៍ប្ដូរសេះសមាជិកក្រុមគាំពិតញាប់, ប្រមូលធាតុគ្រឿងបុព្វពលស្រុកលាវតុង ។

អ្នកស្រីការសានលានជីនាំទឹងតុងចូលបន្ទប់ ជួយផ្លាស់សំលៀកបំពាក់ជាស្រីភេទ, តែគាត់ឆ្ងល់ ត្រង់ឃើញកាយវិការនិងឫកពានាងជាស្រីក្រមុំសុទ្ធសាធ មិនដូចការស្មានរបស់ពួកគាត់ទេ ។

យប់នោះអ្នកភ្ញាហានទាំងអស់កាប់គោ ក្លៃជ្រូក រៀបចំពិធីជប់លៀងមួយជាកិត្តិយសដល់ស៊ីផាន ហើយឲ្យនាយអន្តុយកនូនខ្ពស់ជាងគេជាង ។ ទឹងតុងមិនចង់ឲ្យគេដឹងការពិតទាំងនាងមានគំនិតទាំង មិនហ្វូសប្អូន ក៏ចេះតែធ្វើសញ្ញាឲ្យស៊ីផានពាល់ពេលដែលលោកស្រីការសានឬហ្វានយីហ្វៃសាកសួររកម្ដងៗ ។ នាងចេះតែជួយធ្វើយបន្ទប់យករួចខ្លួន ទាល់តែអ្នកអស់នោះឈប់ដឹកសួរ ។ ការសានលានជីឃើញស៊ីផាននិងទឹងតុងស្និទ្ធស្នាលគ្នាណាស់ , ទឹងតុងមើលអ្នកកម្លោះប្រពៃសុទ្ធតែបក្ខពួកក្រៅក្នុងដំស្រឡាញ់ជាមួយផង ។ លោកស្រីនឹកថា ៖

- អ្នកមានគុណត្រកូលស៊ីនិងប្អូនស្រីរូបនេះច្បាស់ជាគូសន្សារល្អចេញពីផ្ទះហើយ, ពួកយើងមិនត្រូវរំខានលោកទេ

ចំណែកហ្វានយីហ្វៃ, លីធុងកិង និងអ្នកគ្នាព្រួយចិត្តណាស់ ព្រោះគាត់ធ្លាប់ដើរប្លន់ទ្រព្យវិបង់ លាវតុងជាច្រើនដែរ, លើកនេះលើយសៀវធ្វើដំណើរបកផ្លូវទិសបិនហ្វូបប្អូន បកជ័យយ៉ាងផ្លូវចក្រៈស្លាប់ទាំងប្អូននាក់ ។ នៅតាមផ្លូវគេបានសម្លាប់ពួកចោរប៉ុន្មានរាក់ដែរ តែមិនអាចយកមកប្រៀបធៀបជាមួយនាកប្រយុទ្ធដ៏សាហាវនឹងទឹងមិនហ្វូសប្អូនទេ ។ ជាពិសេសលើងកិងតប

ប្រមូលផលផងគេ ព្រោះស៊ីស្យូគាត់ស្លាប់ម្នាក់ ។ ប៉ុន្តែនៅចំពោះមុខស៊ីផាននិងទីងតុងគេខំរក្សាទឹកមុខរីករាយ , ខំស៊ីផឹកផឹកសំរែកម៉ាំង ។

លុះស្រស់ស្រូបរួចហើយការសានលានដីព្រិចភ្នែកឲ្យសញ្ញាទៅហ្វានយ៉ៃហ្វ ហើយចាប់ដៃទីងតុងបញ្ចូលក្នុងបន្ទប់មួយដ៏ស្អាតប្រណីត ។ ហ្វានយ៉ៃហ្វកាន់ដៃស៊ីផាន ។ បន្ទាប់មកគេដើរចេញមកវិញ, លោកស្រីការសានលានដីសើចប្រសប់បក្ខិពថា:

– សូមលោកមានគុណមើលកូនក្រមុំយើងខ្ញុំមើលស្រស់ហើយស្អាតដែរ

ស៊ីផានក្រហមមុខចោលភ្នែកលបសំឡឹងទីងតុងឃើញនាងក្រហមមុខដល់តម្លុតត្រចៀក ញញ់ ខ្សែបត្តុដ៏ស្រទន់មកដែរ, នាយបកពោះគិប ៗ ... ទាំងពីរនាក់បែរមុខចេញរៀងខ្លួន, ការសានលានសើចកក្អឹក:

–នេះអាចចាត់ទុកដូចជាត្រីផ្សំដំណេកដែរតើ នៅរៀនខ្មាសអីទៀត ?

ពោលចប់គាត់លូកដៃចេញពីក្នុងអាវ ហើយរលាស់ដៃយ៉ាងរហ័សចោលកាំបិតស្នៀតមួយ ក៏បត់ទៀននៅលើតុងាចត្និលរលត់ភ្លឹប ងងឹតសូន្យ ។ សន្ទុះកាំបិត មិនទាន់អស់ខ្យល់បន្តដំណើរចេញទៅក្រៅតាមបង្អួចវិវ ។ បន្ទប់នេះងងឹតឈឹង, ការសានលានដីពោលបន្ត :

–សូមជូនពរជ័យសិរីមង្គលដល់លោកអ្នកមានគុណ សូមជួបតែសេចក្តីសុខចំរើនលុះត្រាអវសាន ។ លោកស្រីបិទទ្វារបន្ទប់ឮសូរគ្រាំង ! ស៊ីផាននិងទីងតុងក្តៅមុខភាយ ៗ រំភើបញាប់ញ័រជាខ្លាំង ដើមទ្រូងលោតឌិបឌាក ... ខណៈនោះស្រាប់តែមានសម្លេងមួយស្រែកពីសួនច្បារខាងក្រៅថា :

– បើពិតជាអ្នកក្លាហានត្រឹមត្រូវមែន, ត្រូវចេញមុខមកតទល់គ្នាឲ្យឃើញស្នាដៃ ៗ អ្នកលួចចោលកាំបិតស្នៀតតាមរបៀបនេះ មិនគឺជាជនកំសាកទេឬ ?

ទីងតុងលាន់មាត់ឃឺ រត់ទៅរកស៊ីផាន គេក្តាប់ដៃគ្នាយ៉ាងណែនទឹកអស់សំណើចរៀងខ្លួន :

–ការសានលានដីចោលកាំបិតស្នៀតពន្លត់ភ្លើងទៀនឲ្យយើង „ជួបសេចក្តីសុខចំរើន» បែរជាធ្វើឲ្យអ្នកនៅខាងក្រោយយល់ច្រឡំទៅវិញហ្ន៎ !

ស៊ីផានបង់ស្រែកបញ្ឆោតប្រាប់គេ តែត្រូវបាតដៃមួយទន់ល្អក់បិទមាត់នាយជិត មិនឲ្យស្រែក, ទាណាពបានដៃគឺស្រាវត្តុបទីងតុងភ្លាម ។

ឥនដែលស្រែកជេរពីក្រៅមកទៀត:

–កាំបិតហោះនេះកាចសាហាវណាស់, ប្រហែលជាអាកុនស្រីចង្រៃម្នាក់នៅស្រុកលាវតុងហើយ ។ ពុថានៅស្រុកលាវតុង ម្ចាស់ក្លឹបបានហានម៉ែអីតែម្ដង ជាស្ត្រីមេម៉ាយត្រកូលកាវបេរវិជ្ជាគុនបន្តបន្ទាប់ ក៏ហ៊ានប្រើកាំបិតស្លៀតបែបហ្នឹងសម្លាប់គេដែរ ។ ពួកយើងដូចជាមិនដែលប្រទះកាំបិតទន់ខ្សោយដូច្នេះទេ !

ការសានលានជំពោលកាំបិតស្នៀតទៅប្រាថ្នាតែពន្លត់ភ្លើងទៀនក្នុងបន្ទប់មែន, ឥឡូវគាត់មិនចង់ឲ្យមានទៀនវែងឆ្ងាយក៏បណ្ដោយឲ្យគេជេរស្ដីខ្លះទៅ ។ លោកស្រីជណ្ដឹងសួរថា:

–គេស្គាល់កាំបិតហោះយើងមែន ឬគ្រាន់តែនិយាយប្រឡុយលេងទេ ?

ប៉ុន្តែសម្លេងដដែលស្រែកជៀលពីខាងក្រោមកទៀត:

– ស្រុកលាវតុងមានផ្ទុះដីតូចមួយក្រវ៉ែសោះ មែនគ្នាមានហោរលួចសេះច្រើនម៉ឺនទេ ។ អាចោរគេកាប់នាយក្រុមកាំបិតយ៉ាតស្អីមួយនោះចោលតាំបិតយើតលែងនិយាយហើយ ! វាចេះតែប្រើថ្នាំពុលដើរធ្វើបាបគេប៉ុណ្ណោះ ។ នៅមានអាមួយទៀតគ្មានបានការអីទេ គាន់តែពស់កំញើញគេដើម្បីសុំទានអាចោរម្នាក់ទៀតត្រកូលហ្វានបន្ទំគេឲ្យហៅវាថា កុកស នៅលាវតុង ប្រើតែក្លូនដំបងពីរដើមមួយជាតិហើយ ! ម៉េចៗមិនឲ្យគេសើចពុកពោះផ្ទុះធ្មេញឬ ?

សម្រែកជៀមដាមលាន់មកពីក្រៅនេះ ធ្វើឲ្យអ្នកក្លាហាននៅស្រុកលាវតុងទាំងអស់ប្រែចកមុខគ្រប់គ្នា ដណ្ដឹងសួរថា ពួកគេមានបំណងយ៉ាងណាចំពោះខ្លួន ? លីធីងភិងដកកាំបិតខ្លួនក្រាស់ស្ទុះចេញទៅវិញឃើញផនមួយប្រកំភ្លុងឈរជេរក្ដោងដៃធ្លាជើងយ៉ាងសប្បាយ ។ លីធីងភីងស្រែកសន្ទាប់ :

– នែមិត្ត, ឯងស្រែកឡូឡានៅទីនេះ តើមានគោលបំណងយ៉ាងណាដែរ ?

– បំណងយ៉ាងណា ឬ? គ្រាន់តែឃើញពួកក្លាលសំប៉ែតមកពីស្រុកលាវតុង យើងទឹកភ្នែមចង់តែចាប់ទាំងអស់មកកាប់ញូរហាលនៀតទេ !

លីធីងភីងធ្វើហ៊ុះ, ឆ្លើយតបភ្លាម :

–យើងចេញមកហើយ , ឯងចូលមកកាប់ចុះ !

ពោលចប់គាត់បង្វិលខ្លួនស្ទុះចូលត្រង់កាំបិតកាប់ពេញទំហឹងដល់ខ្លួនផនឆោះភ្លាមជាពីរកំណាត់ត្រឹមចង្កេះខ្ទេចពីន្នាខែកលោមប្រាវហូរជោកដី ។

ហ្វាងយីហៃ, ហ្វុនហេងនិងកាវសានលានជី បង្រៀមកដល់ហ្នឹម ឃើញព្រឹត្តិការណ៍ចម្លែកបែបនេះ ក៏មើលមុខគ្នាឆ្ងល់ភ្លេកឡិនឡង់ , លីធីនតិនស្រឡាំងកាំងជាងគេ ឈរក្អឹងមួយកន្លែងដោយមិននឹកស្មានថា ជនដែលហ៊ានប៉ះពាល់ដល់អ្នកក្វាហានស្រុកលាវតុងជាជនសាមញ្ញឥតចេះយុទ្ធសិល្បៈមួយគ្រាប់ដូច្នេះសោះ, មិនបានអ៊ីកទប់ទល់នឹងគាត់មួយស្នៀតឲ្យអស់ចិត្តផង ។

អ្នកកល់គ្នាកំពុងតែផ្លៀងធ្លល់ឆ្ងល់ក្បាលនៅឡើយស្រាប់តែមានសំឡេងមួយ ស្រែកចំអកពីលើដំបូលផ្ទះមកថា:

– អស្ចារ្យណាស់, អស្ចារ្យមែន ! លោកលីនាយក្រុមកាំបិតញាប់បង្កៀតមួយស្នៀត កាច់អ្នកបរើផ្ទះសំណាក់ដាច់ដាច់ពីកំណាត់ក្លាម ! ហាស ៗ . . .

ទាំងអស់គ្នាងើយមើលដំបូលផ្ទះរកម្ចាស់សម្លេង ៗ គឺជាបុរស ម្នាក់ចំណាស់មធ្យម ឈរស្ងៀមបង្អែះលើដំបូល យ៉ាងសង្ហា ៗ គេភ្ញាក់ព្រើតប្រហែលជាពោះផ្លុង ព្រោះរូបរាងជននេះដូចពីជនដែលឈរខាងក្រោម ពោលពាក្យអសច្ចរស ។ គេយល់ថាជននេះ ច្បាស់ជាកំពូលគុនណាមួយទាត់ឲ្យមកបង្កហេតុជាមួយអ្នកក្វាហានស្រុកលាវតុងទេតើ !

លោកស្រីកាវសានលានជីឥតបាច់គិតច្រើន គ្រវាសដៃស្ដាំបោលកាំបិតស្នៀតតម្រង់ជននោះព្រួសៗ ... ជនលើដំបូលផ្ទះលូកដៃចាប់កាំបិតមួយជាប់ ហើយគេចផុតកាំបិតពីរទៀតសើចក្អាកក្អាយ:

– បើអស់លោកទាំងបួនក្រុមនៅស្រុកលាវតុងអញ្ជើញដល់ទីនេះហើយ, សូមទៅជួបជុំគ្នាត្រង់ព្រៃមួយឆ្ងាយពីនេះប្រហែលដប់ពីរយោជន៍,បើមិនហ៊ានទៅក៏ហើយចុះ !

ជននោះពោលចប់លោតចុះពីដំបូលផ្ទះរត់ចេញបាត់ភ្លាមឥតនឹងចាំចម្លើយផងបាក់ដូចគេខ្លាចញញើតអ្នកក្វាហានស្រុកលាវតុងដែលមានគ្នាច្រើនណាស់ ។

កាវសានលានជីផ្ដើមសួរយោបល់គ្នីគ្នា:

– តិតយ៉ាងម៉េចពួកយើង, ទៅឬកុំទៅ ?

ហ្វាងយីហៃតបដោយមិនបាច់គិតគូរ:

–ទោះពួកនោះជាស្អីក៏ដោយ, បើគេមកប្រកាសសង្គ្រាមជាមួយយើងហើយយើងត្រូវទៅជាដាច់ខាត!

កាវសានលានជីតបភ្លាម:

-មែនហើយ! យើងមិនត្រូវធ្វើឲ្យសាបរលាបកេរ្តិ៍ឈ្មោះអ្នកគុននិយមដំបន់លាវគុនយើងទេ !

បន្ទាប់មក លោកស្រីដើរទៅជិតបន្ទប់ស៊ីផាន ស្រែកពីក្រៅខ្លាំងៗថា:

-លោកប្រុសនិងប្អូនស្រី, ពួកយើងមានការចាំបាច់ទៅជួបគេឥឡូវនេះឯង ។ យើងសុំលាទៅមុនសិនហើយ, ចាំស្អែកសឹមជួបគ្នានៅផ្លូវខាងមុខ ។

លោកស្រីឈប់បន្តិចមិនឮនរណាឆ្លើយទើបបន្ត:

-ទីនេះមានមនុស្សស្លាប់ម្នាក់ហើយ, សូមលោកប្រុសនិងប្អូនស្រីប្រញាប់ចាកចេញទៅ, កុំនៅបង្អែបង្អង់យូរ នាំរំខានចិត្ត ។

គាត់យល់ថាមិនបាច់ហាមាត់សុំអ្នកទាំងពីរទៅជាមួយទេ ព្រោះយល់ថា គេជួយគ្នាគាត់ទាំងអស់ឲ្យរួចពីស្លាប់ ចាត់ជាសំណាងណាស់ហើយ, មិនគួរហៅរកគេទៀតទេ, កុំឲ្យគេថាក្រុមបក្សទាំងប្អូននៅលាវគុងមានតែឈ្មោះ ដូចស្គរប្រហោងក្នុង ។

តិតឃើញដូច្នេះ , គាត់ក៏បបួលគ្នីគ្នាចេញពីសណ្ឋាគារអស់គ្មានសល់ឡើយ ។ ស៊ីផានងាកមើល ទីងតុងសួរយោបល់:

- ឥឡូវយើងគិតធ្វើម៉េច ?

ទីនតុនដកដង្ហើមធំ :

- បើនៅទីនេះមិនបានដដែល, ត្រូវទៅតាមពួកគេមើលលេងទៅណា៎ !

- យី! មិនដឹងពួកគេជាអ្នកណា, តិចលោប៉ះលោកតាទីប្អូនរបស់ហ្វូនទៀតទៅ :

-ខ្ញុំមិនដឹងដែរ, តែយើងទៅងល់ពួនលបមើលគេសិនណា៎ ! កុំអាលបង្ហាញមុខ ។ ប្រហែលលោកតាមែនក៏មិនដឹង ។

-អីចឹងវីវរធំហើយ, ខ្ញុំមិនទៅទេ !

-ឆ្កួត! បើជួបលោកតាមែនយើងមិនបាច់រត់ទេ, ព្រោះឥឡូវនេះបងខ្លាំងពូកែលើសដើមឆ្ងាយណាស់, លោកតាប្រយុទ្ធមិនឈ្នះបងទេ ! ខ្ញុំមិនខ្លាចផង, ម៉េចបងខ្លាចជាងខ្ញុំម្ល៉េះ?

នៅពេលអ្នកទាំងពីរជជែកគ្នា លោកស្រីភាវសានលាន់ជីនិងគ្នីគ្នាលោតផែលលើខ្នងសេះចេញដំណើរបន្តបន្ទាប់គ្នា ។ លោកស្រីស្រែកចុងក្រោយគេ:

-នេះជាប្រាក់ពីររយដប់តម្លឹងណា៎ ! ដប់តម្លឹងសម្រាប់ថ្លៃបន្ទប់និងបាយទឹក, ពីររយតម្លឹងជារង្វាន់ឲ្យ

គ្រួសារអ្នកវេទគ្រោះ ។ ឃាតករដែលសម្លាប់អ្នកបំរើនេះឈ្មោះវ៉ឺន ខ្លាធំជាមេចោរលួចសេះនៅសានតុង,សូមកុំមួលបង្កាច់អ្នកណាឲ្យសោះ!

ស៊ីផានស្សួរទាន់ក្រមុំតិចៗ:

-ម៉េចក៏លេចឈ្មោះវ៉ឺនខ្លាធំមកទៀតហើយ ?

-គេចេះតែរកលេសមកបន្ទុំអាជ្ញាធរកុំឲ្យចាប់ទោសអ្នកស្លុតត្រង់ចុំណ្ណោះទេតើ !

អ្នកទាំងពីរចេញមកក្រៅឃើញសេះមួយគូឈរត្រង់មាត់ទ្វាររង់ចាំជាស្រេច, គេលោតឡើងជិះភ្លាមធ្វើដំណើរទៅកាន់ទិសខាងលិច ។

អ្នកផ្ទះសំណាក់ដឹងថាមានមនុស្សស្លាប់ក្នុងសួនច្បារគ្មាននរណាហ៊ានចេញមកជូនដំណើរឬសាកសួរគៀវទេ ។

ស៊ីផានផានិងទីងតុង បំបោលសេះតាមក្រោយអ្នកក្លាហានទាំងបួននៃក្រុមខាងលាវតុង បានចម្ងាយប្រហែលដប់យោជន៍ទើបឃើញព្រៃមួយដ៏ក្រាស់ខ្មៅងងឹត ។ នាយពុស្សូរសម្លេងហ្វានយីហៀវស្រែកខ្លាំងៗពីចម្ងាយមកថា :

– មិត្តអញ្ជើញមកពីខាងណាដែរ បានជាខំទៅហៅយើងខ្ញុំដល់កន្លែង ? ឥឡូវម្ចាស់ភូមិឋានហានវៃ, ក្រុមកាំបិតញាប់, ក្រុមនាគខៀវនិងក្រុមខ្លាក្រាបនៅលាវតុង បានមកជួបជុំគ្នាតាមពាក្យសន្យាហើយ !

អ្នកក្លាហានទាំងអស់ឈរនៅជាយព្រៃស្រែកសួរសិន ព្រោះគេគោរពពាក្យស្លោកប្រចាំពិភពគុនមួយប្រយោគថា: «បើមានមនុស្សកុំចូលក្នុងព្រៃ» ជាពិសេសរាត្រីងងឹតបែបនេះមិនដឹងសត្រូវបង្កប់ខ្លួនប៉ុន្មាននាក់?

ទីងតុងប្រាប់ស៊ីផានថា:

– យើងពួនត្រង់ណាចាំស្តាប់គេ, ចាំមើលគេសិន , តើលោកតាឃុំមិនមែន ?

អ្នកទាំងពីរលោតចុះពីខ្នងសេះដើរលបៗ ទៅពួនក្រោយគុម្ពថ្មមួយធំ ។ ហ្វានយីហៀវពុស្សូរជើងសេះក៏ដឹងថាអ្នកទាំងពីរមកតាមក្រោយ , តែគាត់មិនធ្វើដឹងឡើយ ។

នាយក្រុមទាំងបួនរូបហៅសិស្សជាងដប់នាក់ ទៅឈររាយគ្នាឆ្ងាយពីព្រៃរង់ចាំសត្រូវ ៗ ព្រៃនេះធំហើយស្ងាត់ស្ងៀម ក្រូវនឹងមេឃស្រអាប់ផង គេមានអារម្មណ៍ព្រឺព្រួច សម្លឹងមុខគ្នាឃើញ

Khmer Story Lovers



ទៀត ៗ ដូចខ្មោចបិសាច ។

មួយសន្ទុះក្រោយទើបឮសម្លេងហួចឆ្វេចឆ្វាចលាន់ចេញពីក្នុងព្រៃ ហើយឃើញមនុស្សពាក់អាវខ្មៅតៗ ចេញមកជាជួរៗ សំដៅអ្នកក្លាហានដំបន់លាវគុង, ក្នុងមួយជួរមានគ្នាប្រហែលប្រាំឬប្រាំមួយនាក់ ។ គេរត់ចេញមកវាយឆ្មក់ព័ទ្ធជុំវិញអ្នកក្លាហានស្រុកលាវគុងព្រមទាំងស៊ុំផាន និងចេងគុងទៀត, មានគ្នាទាំងអស់ប្រមាណជាងមួយរយនាក់ ។ រត់មកដល់កន្លែងរៀងខ្លួន គេឈរស្ងៀមកាន់អាវុធគ្រប់ដៃឥតចេញរកាមួយម៉ាត់ឡើយ ។ បន្ទាប់ពីនោះទើបឃើញជនអាវខ្មៅដប់មួយនាក់ចេញមកទៀត ។

ស៊ុំផានមានភ្នែកភ្លឺមុតក្រឡេកខ្ទាប់លាន់មាត់ឃើ ! ព្រោះជនទាំងនោះសុទ្ធជានាយកនិងនាយកងរងខាងក្រុមឈានល្អ គឺនីហ៊ុងយេ, ឈិនឈុនជ៉, ចាងហៀជាដើម ។ លុះជនដប់មួយនាក់ទៅឈរសងខាងហើយគេឃើញជនម្នាក់ទៀតដើរចេញមកម្នាក់ឯង ។ ជននេះជាលោកគ្រូពេទ្យដៃឆើតនាមពៅហៃស៊ីតែម្តង ។ គ្រូពេទ្យក្អករខះៗផ្ដើមពោលវាចាថា :

– បានអស់លោកទាំងប្អូនអញ្ជើញមក, បងប្អូនយើងទាំងអស់ខះ ! ខះ ៗ ... មានគេត្រេកអរយ៉ាងខ្លាំងទើបមកទទួលដល់ទីនេះ ខះ ! ខះ ! ប៉ុន្តែ ... ខះ ៗ ... ប៉ុន្តែអស់លោកអញ្ជើញមកយឺតបន្តិច ធ្វើឲ្យបងប្អូនយើងរង់ចាំយ៉ាងអន្ទះអន្ទែង ។

ហ្វានយីហៀងងឹងគ្នា គ្រាន់តែឮសម្លេងក្អករខះៗ លាយនឹងវាចា គេស្គាល់ភ្លាមជាពៅហៃស៊ី ងឺស្បៀខាងក្រុមឈានល្អភ្លាម ។ ហ្វានយីហៀងនឹកថា :

– បានជួបជនដែលណាត់ជួបនឹងយើងហើយ ! យើងរំស្កាត់មកពីឆ្ងាយដើម្បីជួបពួកគេ, បើពួកគេជាក្រុមឈានល្អមែន ការស្លាប់រស់ស្ថិតលើតាកប្រយុទ្ធដែលកើតមានក្នុងពេលបន្តិចទៀតនេះឯងនោះ គ្នាគេច្រើនលើសលុបក៏យើងមិនត្រូវខ្លាចដែរ ។ ស្លាប់ដោយសាររឿងនេះប្រសើរជាងស្លាប់ក្រោមស្នាដៃទីងមិនហួសបួនដែលគ្មានការទាក់ទងជាមួយយើងសោះ !

ហ្វានយីហៀងលើកដៃគោរព:

– អូ ! គឺលោកគ្រូពេទ្យដៃឆើតមកទទួលយើងខ្ញុំដល់នេះឬ ? មិនបាច់គួរសមពេកទេ, ខ្ញុំបាទហ្វានយីហៀងនាយក្រុមខ្លាក្រាប ។

បន្ទាប់មកហ្វានយីហៀងណែនាំលីជឹងភិងនិងការសានលានជី ឲ្យស្គាល់ក្រុមឈានល្អ ។ ស៊ុំផាន

លបមើលឃើញតាពៃ និយាយជាមួយអ្នកគ្នាហានស្រុកលាវតុង យ៉ាងកក់ទាក់ដូច្នេះក៏នឹកថា:

- គេមិនមែនរកវាយប្រយុទ្ធគ្នាឯណា ?

នាយពោលតិចៗ ប្រាប់ទីងតុង :

- គ្នាយើងទេទីងៗ តុងៗ,ចេញទៅក្រៅវិញឬ ?

ទីងតុងចាប់ទាញដៃនាយទៅវិញ ឱនខ្សឹបដាក់ត្រចៀកថា:

- ឈប់សិន ! រង់ចាំបន្តិចទៀតមើល ?

ពុស្សូហ្វានយីហៃពោលទៀតថា:

- យើងបានណាត់ជួបគ្នាឯទីចាត់ការក្រុមអស់លោកនេះតើ ! ប៉ុន្តែយើងបានជួបប្រទះរឿងហេតុបន្តិចបន្តួចតាមផ្លូវ ទើបខាតពេលហួសថ្ងៃសន្យា សូមលោកគ្រូពេទ្យនិងអស់លោកនាយក្រុមមេត្តាអភ័យទោសផង ។

ពៃហៃស៊ីតបវិញថា: អរគុណៗ ... ប៉ុន្តែលោកនាយក្រុមរង់ចាំអស់លោកយូរពេក មិនឃើញអញ្ជើញមក ហើយត្រូវលោកមានកិច្ចការផ្ទាល់ខ្លួនផង ក៏នឹកស្មានថា អស់លោកលែងនឹកនាពីរឿងសន្មតជួបគ្នាហើយ ។ ឥឡូវលោកនាយក្រុមយើងលែងរង់ចាំអស់លោកស្រេច ។

ហ្វានយីហៃស្រឡាំងកាំងមួយខណៈទើបសួរបញ្ជាក់:

- លោកនាយក្រុមស៊ីអញ្ជើញទៅណាហើយ ? សុំជំរាបលោកគ្រូពេទ្យតាមត្រង់ចុះ, យើងខ្ញុំស្ពាត់មកពីស្រុកឆ្ងាយមានប្រាថ្នាតែមួយគឺចង់ជួបលោកនាយក្រុមស៊ីម្ដង, ឥឡូវបើមិនបានជួបវិញពួកយើង ... ដូចជា ... ពួកយើងអស់សង្ឃឹមហើយ ។

ទីងតុងខ្សឹបដាក់ត្រចៀកស៊ីធានទៀត:

- ពួកនេះល្ងង់អ្វីម្ល៉េះ ! បានចាំងជប់លៀងបង ជាភ្ញៀវកិត្តិយសផងម្ដេចពោលថារកបងមិនឃើញហើយអស់សង្ឃឹមទៅវិញ ?

ហ្វានយីហៃបង្អង់បន្តិចទើបបន្តថា:

- យើងខ្ញុំបានដឹកនាំផលិតផលនៃស្រុកលាវតុង ដូចជាស្បែកសត្វនិងឫសឈើធ្វើថ្នាំជាដើមមកជូនលោកនាយក្រុមស៊ី, លោកគ្រូពេទ្យនិងអស់លោកនាយត្រួត ។ ជំនូននេះស្ដួចស្ដើងជាទីបំផុត តែសូមអស់លោកទទួលដោយអនុគ្រោះផង, ព្រោះយើងខ្ញុំខំដឹកញ្ជូនមកពីឆ្ងាយជូនអស់

លោកដោយស្មោះអស់ពីចិត្ត

ពោលចប់គាត់ធ្វើសញ្ញាឲ្យសិស្សបីរូបដើរទៅស្រាយកញ្ចប់លើខ្នងសេះមកទុនលំទោនជូនតៃហស៊ុ។

លោកគ្រូតៃញញឹម :

-អស់លោក ... នេះៗ ... ដូចជាគួរសមពេកហើយនេះ ... នេះៗ ... បើអស់លោកមានចិត្តស្មោះត្រង់មែន, ខ្ញុំមិនរុញរាទេ, សូមអរគុណ! អរគុណច្រើន!

បន្ទាប់ពីនោះមក, ហ្វានយីហៃលូកយកកញ្ចប់មួយពីខ្នង គាត់កាន់នៅដៃ ចាំងពីរដើរទៅមុខពីរបីជំហានពោល :

– កាលពីដើមលោកនាយក្រុមតុង ហ្វាន ធ្លាប់អញ្ជើញទៅលេងស្រុកលាវតុងពិភាក្សាជាមួយយើងខ្ញុំយ៉ាងស្និទ្ធស្នាល ម៉្យាងទៀតលោកនាយក្រុមតុង ហ្វាងឥតស្អប់ខ្ពើមយើងខ្ញុំទេ លោកបានចងមិត្តនឹងខ្ញុំទៀតផង ។ កញ្ចប់មួយនេះសុទ្ធតែឫសឈើរាប់រយឆ្នាំ អាចជួយចម្រើនអាយុឲ្យបានយឺនយូរ, ជាវត្ថុកម្រណាស់, ខ្ញុំសូមជូនកញ្ចប់នេះដល់លោកបងតុង ហ្វាងផង ។

ពោលហើយហ្វានយីហៃលើកកញ្ចប់ដល់ក្បាលសម្លឹងមុខតៃហស៊ុ

ស៊ុំជាននៀងឆ្ងល់ជាខ្លាំង ដណ្ដឹងសួរថា :

– ម្ដេចក៏មាននាយក្រុមតុង ហ្វាងអីទៀតហើយ

ពេលនោះតៃហស៊ុក្អកនេះ ១ ដកដង្ហើមធំ :

លោកបងតុង ហ្វាងជាអតីតនាយក្រុមរបស់យើងនោះនេះ ១ បានប្រទះរឿងមួយមិនពេញចិត្តសោះ ទើបលែងរវល់នឹងកិច្ចការផ្ទៃក្នុងរបស់ក្រុមបក្សយើង គាត់បានប្រគល់ភារៈនេះជូននាយក្រុមស៊ុំនេះ ១... ចំណែកខ្លួនគាត់នៅស្នាក់អាស្រ័យក្នុងព្រៃភ្នំបាត់ដំណឹងឈឹងស្ងៀង ។ បងប្អូនខ្ញុំទាំងអស់ក្នុងក្រុមនឹករឭកគាត់ណាស់, ប៉ុន្តែមិនដឹងធ្វើម៉េចអាចជញ្ជូនអំណោយដ៏ក្រាស់ក្រែលនេះដល់ដៃលោកបងតុងហ្វាងបាន ?

ហ្វានយីហៃសួរបញ្ឆាក់ភ្លាម

– លោកបងតុងហ្វាងទៅសម្ងំស្នាក់អាស្រ័យកន្លែងណា ? ដោយហេតុអ្វី ?

សំនួរនេះច្បាស់ណាស់ហើយមុឺងម៉ាត់ណាស់ តៃហស៊ុសើចញញឹម ១ :

– ខ្ញុំបាទនិងបងប្អូនឯទៀតជាអ្នកនៅក្រោមបង្គាប់ លោកនាយក្រុមតុងហ្វាងមិនត្រូវធ្វើដឹងឮចំពោះ

កិច្ចការផ្ទាល់ខ្លួនរបស់លោកនាយក្រុមទេ ។ តើអស់លោកនៅលាវគុនជាមិត្តភក្តិស្និទ្ធស្នាលរបស់លោកនាយក្រុមយើងស្រាប់, ទេះ ។.. ស្រួលហើយ ! យើងខ្ញុំកំពុងចង់សុំសួរលោកថាហេតុអ្វីកិច្ចការក្រុមឈាននល្អកំពុងល្អពេលាស់គ្រប់វិស័យ លោកនាយក្រុមគុនហ្វាងបែរជាប្រគល់អម្រែកជូនឡូលោកស៊ីវិញ ?

សំនួរបញ្ហានេះ ធ្វើឲ្យហ្វានយ៉ាហ្វាពិបាកឆ្លើយណាស់ ។ តៃហ៊ុស៊ីពោលតទៀតថា :

- នៅពេលដែលលោកនាយក្រុមគុនហ្វាងប្រគល់តំណែងឡូលោកស៊ុ , យើងខ្ញុំទាំងអស់គ្នាតែងស្គាល់ប្រវត្តិលោកស៊ុចន្តិចសោះទេ, មិនស្គាល់ចរិយាមារយាទនិងកំរិតយុទ្ធសិល្បៈគេទេ ។ គ្រាន់តែឃើញលោកនាយក្រុមថ្មីនៅក្មេងពេក ឥតកេរ្តិ៍ឈ្មោះក្នុងពិភពគុន ចង់ដឹកនាំក្រុមឈាននល្អ យើងខ្ញុំមិនពេញចិត្តស្រួចទៅហើយ ។ ប៉ុន្តែក្រោយមកលោកនាយក្រុមថ្មីចេះរៀបចំកិច្ចការផ្ទុំក្នុងឲ្យបានល្អពេលាស់គ្រប់ផ្នែក ទើបយើងដែនបានរម្ភ ។ ពេលនោះទើបយើងយល់ថា លោកនាយក្រុមគុនហ្វាងចេះដឹងការច្រើនណាស់, មើលមនុស្សស្គាល់ដល់ចិត្តថ្លើម , ទេះ។... បើមិនដូច្នេះម្តេចគាត់ទៅចងមិត្តជាមួយអស់លោក ហាស់ៗ...

ស៊ីងីលោកគ្រូពៃមានន័យថាបើលោកនាយក្រុមគុនហ្វាងទាក់ទងនឹងអ្នកក្លាហាននៅលាវគុន,លោកជាជនប្រភេទណា អ្នកស្រុកលាវគុនជាជនប្រភេទណា ?

លីឆេងភិងពោល :

-លោកគ្រូពៃ , ដំណឹងដែលយើងបានទទួលនៅលាវគុនមិនដូចសិងលោកទេ , ហេតុនេះបានជាយើងខ្ញុំស្គាល់មកពីឆ្ងាយសាកសួររឿងនេះឲ្យបានច្បាស់លាស់ណា !

តៃហ៊ុស៊ីតបយ៉ាងគោរពគ្រោះថា :

-ពាក្យចចាមអារ៉ាមលេចចេញពីមាត់មួយទៅមាត់មួយយកជាការមិនបានទេ ។ ប៉ុន្តែ អើល៍ ! លោកបានដំណឹងយ៉ាងម៉េចខ្លះដែរ ?

-កាលបើមិនទាន់កែភស្តុតាងឃើញជាក់ស្តែងយើងពេចចាត់ទុកដំណឹងនេះជាពាក្យចចាមអារ៉ាមដែន តែជាដំណឹងដែលគួរជឿបាន ។ ពួមិត្តម្នាក់ប្រាប់យើងថាលោកបងគុនហ្វាងគ្រូ ... គ្រូ ... ( វិក្កកគាត់ជះពន្លឺផ្លេកៗក្នុងយប់ងងឹត ) គ្រូវជនក្បត់ក្នុងក្រុមឈាននល្អធ្វើបាបទាល់តែស្លាប់យ៉ាងអាថ៌កំបាំង, ហើយតំណែងនាយក្រុមត្រូវធ្លាក់ក្នុងកណ្តាប់ដៃយុវជនមួយរូបឈាមងារ, កណ្តា

គ្រាស់, គាំចសាហាវយង់ឃ្នងគ្មានសីលធម៌ក្នុងខ្លួនបន្តិចណាសោះ ។ មិត្តនោះបាននិយាយប្រាប់យើងដោយម៉ឺងម៉ាត់ មិនសមជាពាក្យភូតកុហកឡើយ ។ យើងខ្ញុំធ្លាប់រាប់អានលោកបងតុងហ្វាងនោះដឹងថាកំរិតយុទ្ធសិល្បៈខ្លួនអន់ខ្សោយ មិនគួរជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងក្រុមឈានល្អក៏ដោយ ក៏យើងចេះឈឺឆ្អាលចំពោះមិត្តភក្តិដែរ, ប្រសិនបើមានរឿងដូច្នេះមែនយើងយល់ថាមិនគួរគប្បីទេ ។

ពៃហៃស៊ីសើចហេស ៗ :

— លោកបងលីមានប្រសាសន៍ត្រូវណាស់, ពិតជាមិនគប្បីមែន !

លីធីងភិងក្តៅមុខភាយ ៗ នឹងសំដីចាក់ដណ្តាយនេះ ព្រមទាំងទឹកថា :

— គ្រូពេទ្យដៃជើតល្បីថា ចំណាប់ចំនួនណាស់, ឥឡូវឃើញផ្ទាល់ភ្នែក, ពិតជាដូច្នេះមែន !

លីធីងភិងពោលខ្លាំង ៗ :

អស់លោកចង់លើកអ្នកណាធ្វើនាយក្រុមក៏ស្រេចតែចិត្តលោកទៅ, យើងជាអ្នកក្រៅមិនត្រូវធ្វើដឹងពុទេ ។ យើងមកពីស្រុកលាវតុង គ្រាន់តែចង់ដឹងតើលោកបងតុងហ្វាងនៅឯណា,, ស្លាប់ឬរស់ ? តើគាត់លាលែងពីតំណែងនាយក្រុមដោយចិត្តឯង ឬមានគេចន្ទិតបង្ខំ ?

ពៃហៃស៊ីតបយ៉ាងក្រអឺត :

យើងជាគ្រូកូលពៃមិនស្ទាវចេះដឹងអីមែន តែយើងធ្លាប់មានឈ្មោះក្នុងពិភពគុនដែរ ពាក្យសំដីធ្លាក់ចេញមកហើយយើងមិនលេបទៅវិញទេ ។ ឥឡូវអស់លោកចោទថាយើងកុហកឬ ? បាទ ! ខ្ញុំមិនប្រកែកឡើយ, ទុកដូចជាខ្ញុំកុហកទៅចុះ ។ ហ៊ឹះ ! អស់លោកសុទ្ធសឹងជាអ្នកក្លាហានមានមុខមានមាត់ក្នុងពិភពគុន. លោកចេះឈឺឆ្អាលចំពោះមិត្តភក្តិជាការល្អគួរឲ្យសរសើរណាស់, តែ...ខេះ ៗ... រឿងនេះមិនសមទេ, មិនសមទេ !

ការសានលានជីធ្លាប់ល្បីថាចិត្តល្អ, ចិត្តធូនហើយទូលាយ ។ ពេលនេះពុំពៃហៃស៊ីចោទប្រកាន់ចំពោះមុខ គាត់ទ្រាំមិនបាន, ខឹងប្រឡោតស្រែកគំហក :

— ក្នុងរឿងធ្វើបាបលោកបងតុងហ្វាងនោះ ប្រហែលជាមានលោកគ្រូពៃចូលរួមដែរហើយ ! យើងនាំគ្នាមកសងសឹកឲ្យគាត់ហើយណា ! យើងគ្មានសង្ឃឹមបានវិលទៅស្រុកវិញទេ ។ ឯង, ជាកូនប្រុសដើមទ្រូងប៉ុំហត្ថដែរ ហ៊ានស៊ីត្រូវហ៊ានសង ! ឥឡូវសូមឆ្លើយឲ្យច្បាស់មកមើល៍ តែមួយម៉ាត់បានហើយ. លោកបងតុងហ្វាងស្លាប់ឬរស់ ?

**(នៅមានត)**

ដំកល់ទុកតាមលេខ: ៣៧៩ ចុះថ្ងៃទី ៩-៦-៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់

Khmer Story Lovers